# ឧបសម្ព័ន្ធ ៣.១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៩

## អាជ្ញាប័ណ្ណស្វែងរុករក

---

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការវិនិយោគទុនសិក្សាស្រាវជ្រាវរុករករ៉ែនៅតំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ រវាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន DELCOM CAMBODIA PTE. LTD ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៤។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករក លេខ ២៣៧ ឧរថ.ធរ.អប ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញលិខិតជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១៩០ សជណ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៦ ។
- បានឃើញលិខិតលេខ ៣៣៨ ឧរថ.ធរ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញលិខិតលេខ DC/MINE/013/2009 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ របស់ក្រុមហ៊ុន DELCOM CAMBODIA PTE. LTD ។
- បានឃើញលិខិតចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់ក្រុមហ៊ុន Cambodian WS Mining Industry Holding Ltd ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥) ២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard. Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263

<u>**សំរេច**</u>

<u>**ប្រការ១:**</u> អនុញ្ញាតអោយក្រុមហ៊ុន DELCOM CAMBODIA PTE. LTD មានអាសយដ្ឋាននៅផ្ទះលេខ ២៦ ផ្លូវលេខ ៦០៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែមាសបន្តនៅតំបន់ភ្នំដែក ស្រុករវៀង ខេត្តព្រះវិហារ លើផ្ទៃដីទំហំ ០១ (មួយ) គីឡូម៉ែត្រក្រឡា ដែលមានកូអរដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោណេ | ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|---|---|---|
| A | 4 89 839 | 14 79 000 | C | 4 93 839 | 14 78 750 |
| B | 4 93 839 | 14 79 000 | D | 4 89 839 | 14 78 750 |

<u>**ប្រការ២:**</u> អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល០១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណនេះ ក្រុមហ៊ុនត្រូវបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាព (Feasibility Study) និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) រួចបញ្ជូនសំណុំឯកសារទាំងអស់មកក្រសួង ដើម្បីអោយក្រសួងធ្វើការពិនិត្យ និងសំរេច ក្នុងការចេញអាជ្ញាប័ណ្ណអាជីវកម្មជូន ។

<u>**ប្រការ៣:**</u> ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៤ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

<u>**ប្រការ៤:**</u> អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តព្រះវិហារ និងប្រធានក្រុមហ៊ុន DELCOM CAMBODIA PTE. LTD ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារៈកិច្ចរៀងៗខ្លួន ។

<u>**ប្រការ៥:**</u> អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ_សែម

<u>**ចំលងជូន**</u>

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- -សាលាខេត្តព្រះវិហារ
- -សាលាស្រុករវៀង
- -ដូចប្រការ៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥)២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard, Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263